**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកិច្ចការនារី**
លេខ.....៤៤៤.....កកន/សជក

# សេចក្ដីជូនដំណឹង
## ស្ដីពីការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត
## ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី សម្រាប់ឆ្នាំ២០១៦

**យោង** : លិខិតលេខ ៨៨៧ មស.ក្រខ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ ។

ក្រសួងកិច្ចការនារី សូមជូនដំណឹងដល់បេក្ខជនជានិស្សិត ឱ្យបានជ្រាបថា ក្រសួងនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនទាំងពីរភេទ ឱ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារីចំនួន **៥០ កន្លែង** សម្រាប់ឆ្នាំ ២០១៦ ដូចខាងក្រោម ៖

**១- លក្ខខ័ណ្ឌនៃការប្រឡងជ្រើសរើស** បេក្ខជនទាំងពីរភេទ ត្រូវមាន ៖

ក/ សញ្ជាតិខ្មែរ

ខ/ សម្រាប់ក្របខ័ណ្ឌ **ក** អាយុច្រើនបំផុតត្រឹម ៣០ឆ្នាំ (កើតឆ្នាំ១៩៨៦) មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល

គ/ សម្រាប់ក្របខ័ណ្ឌ **ខ** អាយុច្រើនបំផុតត្រឹម ២៨ឆ្នាំ (កើតឆ្នាំ១៩៨៨) មានសញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល

ឃ/ សម្រាប់ក្របខ័ណ្ឌ **គ** អាយុច្រើនបំផុតត្រឹម ២៥ឆ្នាំ (កើតឆ្នាំ១៩៩១) មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល

ង/ ផ្ដល់អាទិភាពចំពោះបេក្ខជនជាជនពិការ ស្ត្រីជនជាតិភាគតិច និងមន្ត្រីជាប់កិច្ចសន្យាដែលបានបម្រើការងារនៅក្រសួងកិច្ចការនារី

ច/ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ជ្រើសរើសតែបេក្ខនារី

ឆ/ មិនត្រូវបានអនុញ្ញាតបេក្ខជនទាំងពីរភេទដែលមានសញ្ញាបត្រជំនាញ ឆ្មប ពេទ្យសត្វ វិស្វកម្ម និងសំណង់ស៊ីវិល

ជ/ មិនត្រូវបានអនុញ្ញាតឱ្យប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងកិច្ចការនារី ចំពោះបេក្ខជនជាព្រះសង្ឃ ។

**២- ការប្រឡងជ្រើសរើសចំនួន ៥០កន្លែង មានដូចខាងក្រោម ៖**

| ល.រ | អង្គភាពជ្រើសរើស | ចំនួនក្របខ័ណ្ឌ | | | |
|---|---|---|---|---|---|
| | | ក | ខ | គ | សរុប |
| ១ | មន្ទីរកិច្ចការនារីរាជធានីភ្នំពេញ | ១ | | | ១ |
| ២ | មន្ទីរកិច្ចការនារីខេត្តតាកែវ | ២ | | | ២ |

១៧

ផ្លូវត្រុងមាន់ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨០ ៧៣៧ / ៨៨២ ០៤៨
៨៨២ ០៣៩ / ៨៨២ ០៤៩
ទូរសារ : ០២៣ ៨៨០ ៧៣៧

| ល.រ | អង្គភាពជ្រើសរើស | ចំនួនក្របខ័ណ្ឌ | | | |
|---|---|---|---|---|---|
| | | ក | ខ | គ | សរុប |
| ៣ | មន្ទីរកិច្ចការនារីខេត្តកំពត | ៣ | | | ៣ |
| ៤ | មន្ទីរកិច្ចការនារីខេត្តកែប | ២ | | | ២ |
| ៥ | មន្ទីរកិច្ចការនារីខេត្តព្រះសីហនុ | ២ | | | ២ |
| ៦ | -មន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ | ១ | | | ១ |
| | -ការិយាល័យកិច្ចការនារីស្រុកថ្មពួក | ១ | | | ១ |
| | -ការិយាល័យកិច្ចការនារីស្រុកអូរជ្រៅ | ១ | | | ១ |
| ៧ | មន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ | ១ | ២ | | ៣ |
| ៨ | មន្ទីរកិច្ចការនារីខេត្តប៉ៃលិន | ១ | | ១ | ២ |
| ៩ | មន្ទីរកិច្ចការនារីខេត្តសៀមរាប | ៣ | | | ៣ |
| ១០ | -មន្ទីរកិច្ចការនារីខេត្តកំពង់ចាម (មជ្ឈមណ្ឌលអភិវឌ្ឍស្ត្រី) | ១ | | | ១ |
| | -ការិយាល័យកិច្ចការនារីស្រុកស្រីសន្ធរ | ១ | | | ១ |
| | -ការិយាល័យកិច្ចការនារីស្រុកកងមាស | ១ | | | ១ |
| | -ការិយាល័យកិច្ចការនារីស្រុកចំការលើ | ១ | | | ១ |
| ១១ | មន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ | ១ | | | ១ |
| ១២ | -មន្ទីរកិច្ចការនារីខេត្តក្រចេះ | ១ | ១ | | ២ |
| | -ការិយាល័យកិច្ចការនារីស្រុកសំបូរ | | | ១ | ១ |
| ១៣ | មន្ទីរកិច្ចការនារីខេត្តរតនគិរី | ៣ | | | ៣ |
| ១៤ | មន្ទីរកិច្ចការនារីខេត្តមណ្ឌលគិរី | ១ | | | ១ |
| ១៥ | មន្ទីរកិច្ចការនារីខេត្តស្ទឹងត្រែង | ២ | | | ២ |
| ១៦ | -មន្ទីរកិច្ចការនារីខេត្តព្រៃវែង | ១ | | | ១ |
| | -ការិយាល័យកិច្ចការនារីស្រុកពាមរក៍ | ១ | | | ១ |
| ១៧ | មន្ទីរកិច្ចការនារីខេត្តស្វាយរៀង | ២ | | | ២ |
| ១៨ | មន្ទីរកិច្ចការនារីខេត្តកំពង់ឆ្នាំង | ២ | ១ | | ៣ |
| ១៩ | មន្ទីរកិច្ចការនារីខេត្តពោធិ៍សាត់ | ២ | ១ | | ៣ |
| ២០ | មន្ទីរកិច្ចការនារីខេត្តបាត់ដំបង | ២ | | | ២ |
| ២១ | -មន្ទីរកិច្ចការនារីខេត្តកំពង់ស្ពឺ | ២ | | | ២ |
| | -ការិយាល័យកិច្ចការនារីក្រុងច្បារមន | ១ | | | ១ |
| | **សរុបរួម** | ៤៣ | ៥ | ២ | ៥០ |

**៣-វិញ្ញាសាប្រឡង**

ក- វិញ្ញាសាវប្បធម៌ទូទៅ រយៈពេល ១ : ៣០ ម៉ោង

ខ- វិញ្ញាសាកិច្ចការនារី រយៈពេល ១ : ៣០ ម៉ោង

**៤-សំណុំលិខិតដែលត្រូវបំពេញ ៖**

| | |
|---|---|
| -ពាក្យសុំចុះឈ្មោះប្រឡងប្រជែងជ្រើសរើស | ចំនួន ០១ច្បាប់ |
| -ជីវប្រវត្តិសង្ខេប ( មានបិទរូបថតថ្មី ៤ X ៦ ) | ចំនួន ០១ច្បាប់ |
| -សលាកប័ត្រឯកត្តជន ( មានបិទរូបថតថ្មី ៤ X ៦ ) | ចំនួន ០២ច្បាប់ |
| -បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង | ចំនួន ០២ច្បាប់ |
| -សញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ (បញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច) | ចំនួន ០១ច្បាប់ |
| -សញ្ញាបត្រ បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង (បញ្ជាក់ជាផ្លូវការពីអាជ្ញាធរមានសមត្ថកិច្ច) | ចំនួន ០១ច្បាប់ |
| -លិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្ន (ថតចម្លង) | ចំនួន ០១ច្បាប់ |
| -អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ថតចម្លង) | ចំនួន ០១ច្បាប់ |
| -លិខិតបញ្ជាក់សុខភាព (ក្រោយពេលជាប់ជាស្ថាពរ) | ចំនួន ០១ច្បាប់ |
| -លិខិតថ្កោលទោស (ក្រោយពេលជាប់ជាស្ថាពរ) | ចំនួន ០១ច្បាប់ |
| -ជនពិការ (មានលិខិតបញ្ជាក់) | ចំនួន ០១ច្បាប់ |

**៥-កាលបរិច្ឆេទនៃការទទួលពាក្យ ឈប់ទទួលពាក្យ និងការប្រឡង**

-ចាប់ទទួលពាក្យពីថ្ងៃជូនដំណឹងនេះតទៅ និងបញ្ចប់ទទួលពាក្យនៅ*ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០១៦* វេលាម៉ោង ៥ : ០០នាទីល្ងាច ។

-សម័យប្រឡង*ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៦* មណ្ឌលប្រឡងនឹងជូនដំណឹងពេលក្រោយ។

ចំពោះពាក្យប្រឡង និងព័ត៌មានផ្សេងៗ សូមទំនាក់ទំនងមកនាយកដ្ឋានរដ្ឋបាល បុគ្គលិក តាមរយៈលេខទូរស័ព្ទ ០១៦ ៦១២ ៨៥៩/០១៦ ៨២៧ ២៦៩/០១៥ ៨១០ ០១១/០១២ ៣៩៧ ៦៣៨/ ០១២ ៩២៧ ៣០៥/០៨៨ ៦៧៧ ៨៨៨៨ និងមន្ទីរកិច្ចការនារីរាជធានី ខេត្ត នៃក្រសួងកិច្ចការនារី រៀងរាល់ម៉ោងធ្វើការ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រី**

**អ៊ឹង កន្ថាផាវី**

<u>ចម្លងជូន</u>

- គ្រប់ក្រសួង-ស្ថាប័ន "ដើម្បីផ្សព្វផ្សាយ"
- នាយកដ្ឋានព័ត៌មាន "ដើម្បីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងគេហទំព័រ"
- មន្ទីរកិច្ចការនារីរាជធានី ខេត្ត "ដើម្បីមុខការ"